មនសិការខ្មែរ
Moneaksekar Khmer

ថ្ងៃសុក្រ ទី ១៧ ខែសីហា ឆ្នាំ២០០៧

Mr. Kong Korm: Must find justice for the former Buddhist monk Tim Sakhorn.
Description: Statement of SRP Senator Kong Korm, SRP Vice President and Senate's Religious and Cult Affairs Committee # 7 Chairman, supports the perseverance and non-violent struggles of the Khmer Kampuchea Krom people in Kampuchea Krom, the Kingdom of Cambodia and around the globe in their demands for liberty and the return of Ven. Tim Sakhorn to Cambodia.
Moneaksekar Khmer Fri 08/17/07

លោក គង់ គាំ ៖ ត្រូវតែរកយុត្តិធម៌ ចំពោះអតីតព្រះសង្ឃ ទឹម សាខន

សេចក្តីថ្លែងការណ៍

ប្រធានគណៈកម្មការទី៧ ព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ទទួលកិច្ចការមួយផ្នែកលើវិស័យធម្មការ សាសនា សូមគាំទ្ររាល់ការពុះពារ និងទាមទារដោយសន្តិវិធីរបស់ខ្មែរកម្ពុជាក្រោម ទាំងនៅលើទឹកដីកំណើត ទាំងស្ថិតនៅព្រះរាជាណាចក្រកម្ពុជា និងនៅទូទាំងពិភពលោក ដែលមានអង្គការជាតិ អន្តរជាតិជួយគាំទ្រផង កំពុងទាមទារសិទ្ធិសេរីភាពរបស់ខ្មែរកម្ពុជាក្រោមជាទូទៅ និងតវ៉ាចំពោះការផ្សឹកព្រះចៅអធិការ *ទឹម សាខន* វត្តភ្នំដិនខាងជើង ឃុំភ្នំដិន ស្រុកគិរីវង្ស ខេត្តតាកែវ តាមទម្រង់ប្រាសចាកអភិសមាចារព្រះពុទ្ធសាសនា មិនស្របវង្គធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា នៃសំណើលេខ៩០២/០៧-ស.ធ.ក.ជ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០០៧ របស់សម្តេចសង្ឃនាយក *នន្ទ ង៉ែត* និងចំណាររបស់អគ្គមហាសង្ឃរាជគណៈមហានិកាយ *ទេព វង្ស* ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០០៧ ក្រោមបទចោទប្រកាន់ថា ព្រះសង្ឃ *ទឹម សាខន* ធ្វើឱ្យខូចខាតដល់ទំនាក់ទំនងកម្ពុជា-វៀតណាម ហើយក្រោយមកត្រូវអាជ្ញាធរវៀតណាម បានចាប់ខ្លួនអតីតព្រះសង្ឃ *ទឹម សាខន* ដាក់គុកនៅប្រទេសវៀតណាម អំពីបទឆ្លងដែនខុសច្បាប់ និងអំពីការជួយសហព័ន្ធខ្មែរកម្ពុជាក្រោម ដែលបំបែកបំបាក់សាមគ្គីភាពវៀតណាម-កម្ពុជា ដោយគ្មានភស្តុតាងអ្វីទាំងអស់ ។

តាមហេតុដើម និងដំណើរកែសម្រួល ដែលខ្វះហេតុផលអំពីបញ្ហាព្រះសង្ឃ *ទឹម សាខន* នៅព្រះរាជាណាចក្រកម្ពុជា និងនៅសាធារណរដ្ឋសង្គមនិយមវៀតណាមនេះ មតិជាតិ និងអន្តរជាតិ ចាត់ទុកថាជាការមួលបង្កាច់ និងជាអំពើរំលោភសិទ្ធិមនុស្សដ៏ធ្ងន់ធ្ងរ និងដ៏គ្រោះថ្នាក់បំផុត ។ ម្យ៉ាងទៀត ការអនុវត្តន៍នយោបាយតែមួយរួមគ្នានៃការបង្ក្រាបសិទ្ធិសេរីភាពព្រះសង្ឃ និងខ្មែរកម្ពុជាក្រោម របស់ប្រទេសទាំងពីរនៅពេលនេះ គឺរឹតតែបញ្ជាក់ថា ព្រះរាជាណាចក្រកម្ពុជាកាន់តែធ្លាក់ចុះនូវអធិបតេយ្យភាព បូរណភាព និងឯករាជ្យភាពរបស់ខ្លួនយ៉ាងខ្លាំងថែមទៀត ។

ដូចការកត់សម្គាល់ខាងលើ ខ្ញុំសូមជូនពរ និងគាំទ្រពេញទំហឹងចំពោះរាល់ការខិតខំ និងសកម្មភាពតវ៉ាទាមទារដោយសន្តិវិធីរបស់សហគមន៍ខ្មែរកម្ពុជាក្រោមរបស់មជ្ឈដ្ឋានជាតិ អន្តរជាតិ សំដៅជួយជំរុញឱ្យរដ្ឋាភិបាលកម្ពុជា និងវៀតណាម ត្រូវតែរកយុត្តិធម៌ចំពោះអតីតព្រះសង្ឃ*ទឹម សាខន* និងត្រូវតែផ្តល់សិទ្ធិសេរីភាពចំពោះខ្មែរកម្ពុជាក្រោមស្របតាមសន្ធិសញ្ញា និងសេចក្តីថ្លែងការណ៍ជាសាកលស្តីពីសិទ្ធិមនុស្សមនុស្សជាចាំបាច់ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៧

ហត្ថលេខា *គង់ គាំ* ប្រធានគណៈកម្មការទី៧ នៃព្រឹទ្ធសភា៕